# អនុក្រឹត្យ លេខ៤២ អនក្រ.បក

## ស្ដីពី

## ស្តង់ដារឧស្សាហកម្មកម្ពុជា

៙៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០១

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការគ្រប់គ្រងស្តង់ដារូបនីយកម្មក្នុងវិស័យឧស្សាហកម្ម ដែលស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណង :

-បង្កើនសមត្ថកិច្ចក្នុងការគ្រប់គ្រងផលិតកម្មឧស្សាហកម្ម និងផ្ដល់នូវទំនុកចិត្ត ដល់វិនិយោគិន ហើយបំពេញបន្ថែមនូវសក្ដានុពលដ៏បរិបូណ៌ដល់ផ្នែកសេដ្ឋកិច្ចទីផ្សារ

-ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផលឧស្សាហកម្ម

-បង្កើនប្រសិទ្ធភាពផលិតកម្មឧស្សាហកម្ម និងធ្វើឱ្យផលិតកម្មមានភាពសមស្រប

-ធ្វើឱ្យសកម្មភាពពាណិជ្ជកម្មកាន់តែប្រសើរឡើង និងងាយស្រួល

-បង្កឱ្យការប្រើប្រាស់ផលិតផលឧស្សាហកម្មមានលក្ខណៈងាយស្រួល

-លើកកំពស់សុខុមាលភាពសាធារណៈ ។

**មាត្រា ៣ .-**

ការបកស្រាយនៃវាក្យសព្ទក្នុងអនុក្រឹត្យនេះ :

-អ្នកស្នើសុំ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលមួយដែលមកសុំអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

-ស្តង់ដារ មានន័យថាឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច ហើយឯកសារនោះផ្តល់នូវក្បួន គោលការណ៍ណែនាំ ឬចរិតលក្ខណៈសំរាប់សកម្មភាព ឬ លទ្ធផលរបស់វាទុកសំរាប់ប្រើប្រាស់ជារួម និងប្រើប្រាស់ឡើងវិញ ដើម្បីធានាឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ ។

-ស្តង់ដារូបនីយកម្ម គឺជាសកម្មភាពបង្កើតស្តង់ដារក្នុងវិស័យឧស្សាហកម្ម ។

-ស្តង់ដារព្រាង គឺជាស្តង់ដារដែលបានដាក់ស្នើសុំយោបល់ ។

-ស្តង់ដារបញ្ជា គឺជាស្តង់ដារមួយដែលតំរូវឱ្យអនុវត្តតាមជាចាំបាច់ ។

-អាជ្ញាប័ណ្ណ គឺជាលិខិតអនុញ្ញាត ដែលបានចេញឱ្យតាមការស្នើសុំដើម្បីប្រើស្តង់ដារ ឧស្សាហកម្ម ឬសញ្ញាសំគាល់ ។

-វិញ្ញាបន័ត្រចុះបញ្ជី គឺជាលិខិតបញ្ជាក់សេចក្តីដែលបានចេញឱ្យ ដើម្បីបញ្ជាក់ទទួលស្គាល់លើប្រព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស ទៅតាមការតំរូវនៃស្តង់ដារ ISO 9000 និង ISO 14000 ។

-សញ្ញាសំគាល់ សំដៅដល់សញ្ញាសំគាល់ស្តង់ដារឧស្សាហកម្ម ។

-ប្រព័ន្ធទទួលស្គាល់មន្ទីរពិសោធន៍ ជាប្រព័ន្ធមួយដែលផ្តល់ឱ្យមានការធានារ៉ាប់រងជា ឯករាជ្យលើសមត្ថកិច្ចរបស់មន្ទីរពិសោធន៍ និងសុពលភាពនៃការក្រិតខ្នាត ឬទិន្នន័យនៃការធ្វើតេស្តដែលមន្ទីរពិសោធន៍ទាំងនោះបានធ្វើ ។

## ជំពូកទី ២

## ភារកិច្ច និងការគ្រប់គ្រង

**មាត្រា ៤ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវទទួលបន្ទុកគ្រប់គ្រងលើស្តង់ដារូបនីយកម្មតាមការកំណត់នៃអនុក្រឹត្យនេះ ។

**មាត្រា ៥ .-**

ក្នុងការគ្រប់គ្រងស្តង់ដារូបនីយកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវអនុវត្តភារកិច្ចដូចខាងក្រោម :

-ជំរុញ និងផ្សព្វផ្សាយពត៌មានតាមមធ្យោបាយបោះពុម្ពជាព្រឹត្តិប័ត្រ ឬចុះក្នុងសារពត៌មាន និងមធ្យោបាយដទៃទៀត ដល់សាធារណជនទាំងក្នុង និងក្រៅប្រទេស

-ធ្វើការណែនាំលើបណ្តាបែបបទ លិខិតស្នាមទាំងឡាយដែលត្រូវបំពេញក្នុងការសុំ អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស ទៅតាមការតំរូវនៃស្តង់ដារ ISO 9000 និង ISO 14000

-សហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើសវនកម្ម ដើម្បីវាយតំលៃលើប្រព័ន្ធគ្រប់គ្រងតាមស្តង់ដារ ISO 9000 និង ISO 14000

-ពិនិត្យ ធ្វើតេស្ត ឬវិភាគលើវត្ថុ ផលិតផល សំភារៈ និងសារធាតុផ្សេងៗ សំរាប់ផលិតកម្មឧស្សាហកម្មក្នុងវិស័យឧស្សាហកម្ម ដើម្បីអនុវត្តការវាយតំលៃលើភាពសមស្រប

-រួមសហការបង្កើតនូវវិធានការការពារប្រឆាំងទៅនឹងទំនិញអន់គុណភាព គ្មានសុវត្ថិភាព

-ចេញអាជ្ញាប័ណ្ណស្តង់ដារផលិតផលឧស្សាហកម្ម ឬវិញ្ញាបនប័ត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងតាមស្តង់ដារ ISO 9000 និង ISO 14000

-ផ្តល់ពត៌មានបច្ចេកទេសអំពីស្តង់ដារូបនីយកម្ម

-រៀបចំ ព្រាង បង្កើត កែប្រែ និងកែលំអស្តង់ដារឧស្សាហកម្ម កម្ពុជា

-ជំនួយការក្នុងការបង្កើតនូវប្រព័ន្ធទទួលស្គាល់មន្ទីរពិសោធន៍

-ផ្តល់ការប្រើប្រាស់រាល់សញ្ញាសំគាល់ស្តង់ដារឧស្សាហកម្មកម្ពុជា

-រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រី បុគ្គលិក ក្នុងស្ថាប័នរដ្ឋ និងឯកជន ជាលក្ខណៈជាតិ តំបន់ ឬអន្តរជាតិក្នុងវិស័យស្តង់ដារូបនីយកម្ម

-ចូលរួមសហប្រតិបត្តិការជាមួយអង្គការស្តង់ដារបរទេស អង្គការស្តង់ដារតំបន់ និងអង្គការអន្តរជាតិ ខាងស្តង់ដារូបនីយកម្ម ISO

-រួមសហការជាមួយក្រសួង ឬស្ថាប័នមានសមត្ថកិច្ចផ្សេងៗដែលពាក់ព័ន្ធ ដើម្បីចុះធ្វើអធិការកិច្ចដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ក្នុងករណីចាំបាច់

-រួមសហការការពារអ្នកប្រើប្រាស់ ជាពិសេសទៅលើសុវត្ថិភាព និងប្រឆាំងទៅនឹងអ្វីដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុខភាព

-សំរបសំរួល និងសហប្រតិបត្តិការក្នុងការវាយតំលៃលើភាពសមស្រប ដែលបានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកក្នុងសមាគមអាស៊ាន ក៏ដូចជាសហគមន៍អន្តរជាតិនានា

-ចូលរួមជាលក្ខណៈអន្តរជាតិ ក្នុងការងារទាំងឡាយដែលពាក់ព័ន្ធទៅនឹងស្តង់ដារូបនីយកម្ម និងការធ្វើឱ្យមានភាពចុះសំរុងគ្នា អំពីស្តង់ដារ ។

**មាត្រា ៦ .-**

នីតិវិធី និងទំរង់បែបបទចំពោះការស្នើសុំអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី និងសុពលភាពនៃការប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៧ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតនូវគណៈកម្មការបច្ចេកទេសស្តង់ដារឧស្សាហកម្ម សំរាប់ជំនួយការក្នុងស្តង់ដារូបនីយកម្ម ឧស្សាហកម្ម ។

**មាត្រា ៨ .-**

សមាជិកគណៈកម្មការបច្ចេកទេសស្តង់ដារឧស្សាហកម្ម ត្រូវមានចំណេះដឹង និងបទពិសោធន៍ក្នុងជំនាញ ហើយមានសមាសភាព :

| | |
|---|---|
| -ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រធាន |
| -ក្រសួងពាណិជ្ជកម្ម | សមាជិក |

| | |
|---|---|
| -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| -ក្រសួងសុខាភិបាល | សមាជិក |
| -ក្រសួងបរិស្ថាន | សមាជិក |
| -ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| -ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| -រាជបណ្ឌិតសភា | សមាជិក |
| -សកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| -សកលវិទ្យាល័យ វិទ្យាសាស្ត្រ សុខាភិបាល | សមាជិក |
| -សកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| -វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| -វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| -សភាពាណិជ្ជកម្ម | សមាជិក |
| -សមាគមអ្នកប្រើប្រាស់ | សមាជិក |
| -សមាគមអ្នកផលិត | សមាជិក |

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មការបច្ចេកទេសស្តង់ដារឧស្សាហកម្ម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៩ .-**

គណៈកម្មការបច្ចេកទេសស្តង់ដារឧស្សាហកម្ម ត្រូវបំពេញនូវរាល់កិច្ចការដែលទាក់ទងទៅនឹងការវាយតំលៃលើប្រធានបទពាក់ព័ន្ធក្នុងស្តង់ដារូបនីយកម្មឧស្សាហកម្ម និង ការធ្វើឱ្យមានភាពចុះសំរុងអំពីស្តង់ដារ ។

## ជំពូកទី ៣

## ស្តង់ដារូបនីយកម្ម និង ការធានាគុណភាព

**មាត្រា ១០ .-**

១-នៅពេលដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវការបង្កើតស្តង់ដារណាមួយក្រសួងត្រូវផ្សព្វផ្សាយស្តង់ដារនោះជាសាធារណៈ ហើយស្តង់ដារនោះត្រូវបានចាត់ទុកថាជាស្តង់ដារព្រាង ។

២-ជនណាដែលមានការជំទាស់ អាចតវ៉ាទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាលាយលក្ខអក្សរដោយបង្ហាញ និងបញ្ជាក់អំពីមូលហេតុជំទាស់ទៅនឹងស្តង់ដារព្រាងនោះ ក្នុងរយៈពេលសែសិបប្រាំថ្ងៃ ចាប់ពីថ្ងៃចេញសេចក្តីប្រកាសតាមមាត្រា ១០ កថាខ័ណ្ឌទី១ ។

៣-ជនណាដែលមានការពាក់ព័ន្ធអាចពិនិត្យគ្រប់ចំណុចនៃស្តង់ដារព្រាងនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

៤-ក្រសួងអាចប្រកាសផ្សាយជាសាធារណៈ នូវស្តង់ដារណាមួយជាផ្លូវការបានក្រោយពី :

ក-រយៈពេលសែសិបប្រាំថ្ងៃ ចាប់ពីការផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដារព្រាងយោងតាមមាត្រា ១០ កថាខ័ណ្ឌទី១ និង

ខ-បានធ្វើការវិនិច្ឆ័យ ចំពោះការជំទាស់ ឬ ការតវ៉ាណាមួយរួច ដូចមានចែងក្នុងមាត្រា ១០ កថាខ័ណ្ឌទី២ ។

៥-ការបង្កើតស្តង់ដារផ្លូវការ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១១ .-**

១-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវប្រកាសជាសាធារណៈ នៅពេលដែលក្រសួងមានបំណងកែសំរួល កែប្រែ ឬដកចេញស្តង់ដារណាមួយ ។

២-ជនណាដែលមានការពាក់ព័ន្ធ អាចតវ៉ាដើម្បីសុំដោះស្រាយជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាលាយលក្ខអក្សរ ឬបង្ហាញឱ្យឃើញភាពពាក់ព័ន្ធលើសំណើកែសំរួល កែប្រែ ឬដកចេញនូវស្តង់ដារនោះ ក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃចេញសេចក្តីប្រកាស ដូចមានចែងក្នុងកថាខ័ណ្ឌទី១ មាត្រា១១ ។

៣-ជនណាដែលមានការពាក់ព័ន្ធអាចពិនិត្យលើរាល់សំណើ នៃការកែសំរួល កែប្រែ ឬការបន្ថែមបន្ថយក្នុងស្តង់ដារនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបាន ។

៤-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចប្រកាសជាសាធារណៈអំពីការកែសំរួល កែប្រែ ឬដកចេញនូវស្តង់ដារណាមួយបានក្រោយពី :

ក-រយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃចេញសេចក្តីប្រកាសជាសាធារណៈ ដែលមានចែងនៅក្នុងមាត្រា ១១ កថាខ័ណ្ឌទី១ និង

ខ-បានធ្វើការវិនិច្ឆ័យ ចំពោះការជំទាស់ ឬ ការតវ៉ាណាមួយ ដូចមានចែងក្នុងមាត្រា ១១ កថាខ័ណ្ឌទី២ ។

៥-ការដាក់ឱ្យអនុវត្តជាផ្លូវការនូវស្តង់ដារដែលបានកែសំរួល ឬកែប្រែ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា ១២ .-

រាល់សញ្ញាសំគាល់ស្តង់ដារឧស្សាហកម្មកម្ពុជា ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ត្រូវមានរូបគំនូរ ក្នុងនោះមានពាក្យពេចន៍ រូបរាង ពណ៌ ឬ និមិត្តសញ្ញា ហើយត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា ១៣ .-

១-អ្នកស្នើសុំអាជ្ញាប័ណ្ណស្តង់ដារ ចំពោះផលិតផល ឬខ្សែសង្វាក់ផលិតកម្ម ត្រូវធ្វើទំរង់បែបបទស្នើសុំទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ក្រសួងអាចធ្វើសំណូមពរឱ្យផ្តល់ពត៌មានបន្ថែមទៀតពីអ្នកស្នើសុំ ឬចាត់មន្ត្រីមានសមត្ថកិច្ចឱ្យចុះពិនិត្យដល់ទីកន្លែង បើមានការចាំបាច់ ។

២-ចាប់ពីបានទទួលពាក្យសុំស្របតាម កថាខ័ណ្ឌទី១ នៃមាត្រា១៣ ប្រសិនបើក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ពិនិត្យឃើញថា ផលិតផលឬខ្សែសង្វាក់ផលិតកម្មនោះ ស្របទៅតាមស្តង់ដារហើយក្រសួងត្រូវផ្តល់អាជ្ញាប័ណ្ណដល់អ្នកស្នើសុំ ដើម្បីបានប្រើប្រាស់សញ្ញាសំគាល់ស្របតាមរយៈពេល និងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់អាជ្ញាប័ណ្ណ ដូចមានចែងក្នុងប្រកាសរបស់ក្រសួង ។

៣-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិគ្រប់ពេលវេលាក្នុងការ :

ក-ព្យួរទុកអាជ្ញាប័ណ្ណក្នុងរយៈពេលមួយមិនលើសពីប្រាំមួយខែ ឬ

ខ-ដកហូតអាជ្ញាប័ណ្ណ ។

៤-មុននឹងព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណណាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវ :

ក-ជូនដំណឹងពីបំណងរបស់ខ្លួនដល់អ្នកកាន់អាជ្ញាប័ណ្ណឱ្យបានដប់ប្រាំថ្ងៃមុន និង

ខ-បញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនោះ នូវមូលហេតុណាមួយដែលនាំឱ្យមានការស្នើសុំព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណ ។

៥-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចស្នើដល់អ្នកកាន់អាជ្ញាប័ណ្ណ ជាលាយលក្ខអក្សរ :

ក-ដើម្បីបញ្ជូនគំរូតាងផលិតផលណាមួយ ដែលបានចេញអាជ្ញាប័ណ្ណរួចហើយ នៅក្នុងកំឡុងពេលដែលបានកំណត់ដាក់លាក់ក្នុងសំណើ ឬ

ខ-ដើម្បីផ្តល់ដល់ក្រសួងនូវពតិមានដែលទាក់ទងទៅនឹងផលិតផល ឬខ្សែសង្វាក់ផលិតកម្ម ឬប្រព្រឹត្តិកម្មនៃផលិតផលនៅក្នុងកំឡុងពេលដែលបានកំណត់ដាក់លាក់ក្នុងសំណើ ។

៦-ក្នុងការលក់ផលិតផលណាមួយ គ្មានជនណាអាចយោងលើស្តង់ដារឧស្សាហកម្មកម្ពុជាធ្វើជាបង្អែក ក្នុងបំណងបំភាន់ឱ្យមានការយល់ច្រឡំថា ផលិតផលនោះត្រូវបានផលិតតាមស្តង់ដារឧស្សាហកម្មកម្ពុជានោះឡើយ ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី លុះត្រាតែផលិតផលនោះត្រូវបានផលិតដោយមានអាជ្ញាប័ណ្ណ និងបានប្រើសញ្ញាសំគាល់ស្តង់ដារឧស្សាហកម្មកម្ពុជា ដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រា១៣នេះ ។

៧-ថ្វីបើមានមាត្រា១៣ កថាខ័ណ្ឌទី៦ ជនណាដែលបានអនុវត្តតាម ឬបានផលិតផលស្របតាមស្តង់ដារដោយឡែកណាមួយនោះ ត្រូវរាយការណ៍ជាលាយលក្ខអក្សរ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីកិច្ចសន្យា ការដកស្រង់ ការស្នើសុំផ្តល់ ឬឯកសារយោងនានាដែលផលិតផល នោះត្រូវបានផលិតតាម ប្រសិនបើមានការតំរូវ ។

មាត្រា ១៤ .-

១-អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវដាក់តាំងអាជ្ញាប័ណ្ណនៅកន្លែងដែលអាចមើលឃើញ ងាយស្រួលក្នុងគ្រឹះស្ថានដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ។

២-ក្នុងករណីអាជ្ញាប័ណ្ណត្រូវបាត់បង់ ឬខូចខាត អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណជំនួសទៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងកំឡុងពេលសាមសិបថ្ងៃ ចាប់តាំងពីថ្ងៃដែលបានដឹងថាបាត់ឬខូច ។

៣-នៅពេលផ្លាស់ប្តូរទីតាំងនៃក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលមានបញ្ជាក់ ក្នុងអាជ្ញាប័ណ្ណអ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងទៅក្រសួងឧស្សាហ កម្ម រ៉ែ និង ថាមពល ។

មាត្រា ១៥ .-

១-អាជ្ញាប័ណ្ណដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសុពលភាព ៣ឆ្នាំ និងអាចបន្តជាថ្មី សំរាប់រយៈពេលដដែលបាន ដោយផ្អែកលើការស្នើសុំ និងការបានអនុវត្តត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដែលបានកំណត់ ។

២-ការផ្ទេរអាជ្ញាប័ណ្ណអាចធ្វើទៅបាន ។ បែបបទនៃការផ្ទេរអាជ្ញាប័ណ្ណនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

៣-អាជ្ញាប័ណ្ណ មួយត្រូវអស់សុពលភាព នៅពេលដែល :

ក-ផុតសុពលភាព

ខ-អ្នកកាន់អាជ្ញាប័ណ្ណបញ្ឈប់ការធ្វើអាជីវកម្មរបស់ខ្លួន ឬ

គ-មានការជូនដំណឹងអំពីស្តង់ដារថ្មី ការកែប្រែ និងការដកហូតស្តង់ដារដែលពាក់ព័ន្ធនឹងផលិតផលបានចូលជាធរមាន ។

៤-នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណបញ្ឈប់ការធ្វើអាជីវកម្មរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណនោះត្រូវជូនដំណឹង ដល់ក្រសួងជាលាយលក្ខអក្សរ មិនឱ្យលើសពីរយៈពេលសាមសិបថ្ងៃ គិតចាប់តាំងពីថ្ងៃបញ្ឈប់ ។

**មាត្រា ១៦ .-**

រាល់បែបបទពាក់ព័ន្ធនឹងវិញ្ញាបនប័ត្រចុះបញ្ជី មានចែងដូចតទៅ :

១-រាល់អ្នកស្នើសុំវិញ្ញាបនប័ត្រចុះបញ្ជីដើម្បីបញ្ជាក់លើប្រព័ន្ធគ្រប់គ្រងតាមស្តង់ដារ ISO ៩០០០ និង ISO 14000 ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ហើយក្រសួងអាចធ្វើសំណូមពរ ឱ្យផ្តល់ពត៌មានបន្ថែមទៀតអំពីអ្វីដែលចាំបាច់ ។

២-ចាប់ពីពេលដែលបានទទួលពាក្យសុំតាមមាត្រា ១៦ កថាខ័ណ្ឌទី ១ ប្រសិនបើសំណុំលិខិតស្នើសុំបានបំពេញគ្រប់គ្រាន់និងបានប្រតិបត្តិតាមល័ក្ខខ័ណ្ឌតំរូវនៃស្តង់ដារពាក់ព័ន្ធ ដោយមានការបញ្ជាក់ពីស្ថាប័នពាក់ព័ន្ធ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អាចចេញវិញ្ញាបនប័ត្រចុះបញ្ជីឱ្យដល់អ្នកស្នើសុំ ឱ្យស្របទៅតាមរយៈពេល និងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់វិញ្ញាបនប័ត្រដូចមានចែងក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

៣-ក្នុងករណីអ្នកកាន់វិញ្ញាបនប័ត្រចុះបញ្ជីមិនអនុវត្តតាមការតំរូវនៃប្រព័ន្ធគ្រប់គ្រង ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អាចព្យួរទុកវិញ្ញាបនប័ត្រចុះបញ្ជីក្នុងរយៈពេលមួយមិនលើសពីប្រាំមួយខែ ឬដកហូតវិញ្ញាបនប័ត្រចុះបញ្ជីមកវិញ ។

៤-មុននឹងព្យួរទុក ឬដកហូតវិញ្ញាបនប័ត្រចុះបញ្ជីមួយ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ត្រូវជូនដំណឹងពីបំណងរបស់ខ្លួនដល់អ្នកកាន់វិញ្ញាបនប័ត្រចុះបញ្ជី ឱ្យបានដប់ប្រាំថ្ងៃមុន ព្រមទាំងបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនោះនូវមូលហេតុណាមួយ ដែលនាំឱ្យមានការព្យួរទុក ឬដកហូតវិញ្ញាបនប័ត្រចុះបញ្ជី ។

**មាត្រា ១៧ .-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញសេចក្ដីជូនដំណឹងមួយដែលនឹងត្រូវចុះផ្សាយក្នុងសារពត៌មាន និងមធ្យោបាយដទៃទៀត អំពីអ្វីដែលទាក់ទងទៅនឹងការផ្ដល់ឱ្យការព្យួរទុក ឬការដកហូតអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី ។

**មាត្រា ១៨ .-**

១-ជនណាដែលពុំសុខចិត្ត ចំពោះសេចក្ដីសំរេចរបស់ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល លើ :

ក-ការបដិសេធ ឬជំទាស់ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី

ខ-ការព្យួរទុក ឬ ការដកហូតអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី

អាចតវ៉ាមកក្រសួងដើម្បីសុំឱ្យបញ្ជាក់បន្ថែម កែប្រែ ឬចាត់ទុកជាមោឃៈនូវសេចក្ដីសំរេចនោះ ។

២-ការតវ៉ាត្រូវធ្វើក្នុងកំឡុងពេលដប់ប្រាំថ្ងៃ ចាប់ពីថ្ងៃដែលសេចក្ដីសំរេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានជូនដំណឹងដល់អ្នកស្នើសុំ ឬដល់អ្នកកាន់អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី ។

៣-សេចក្ដីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការព្យួរទុក ការដកហូតអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជីដែលបានចេញឱ្យជនណាមួយនោះ ត្រូវអស់សុពលភាពនៅពេលការតវ៉ាមួយ ដូចមានចែងក្នុងមាត្រា១៨ កថាខ័ណ្ឌទី១ មានភាពត្រឹមត្រូវ ។

**មាត្រា ១៩ .-**

១-ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល អាចចេញប្រកាសជាផ្លូវការ នូវស្តង់ដារមួយឱ្យទៅជាស្តង់ដារបញ្ជាដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃដែលបានកំណត់បញ្ជាក់នៅក្នុងប្រកាស ដោយយោងទៅតាមបញ្ញត្តិទាំងឡាយដែលបានចែងក្នុងមាត្រា ១៩ នេះ ។

២-នៅពេលដែលក្រសួងមានបំណងចេញប្រកាសស្តង់ដារបញ្ជាណាមួយ ក្រសួងត្រូវផ្សព្វផ្សាយស្តង់ដារនោះជាសាធារណៈ ដើម្បី :

ក-បញ្ជាក់ពីគោលបំណង

ខ-ឱ្យជនណាដែលមានការជំទាស់ សរសេរពីបំណងជំទាស់

ជាលាយលក្ខអក្សរជូនដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ការជំទាស់នោះមិនត្រូវឱ្យយឺតជាងហុកសិបថ្ងៃក្រោយពីថ្ងៃផ្សព្វផ្សាយ ។

៣-ពេលដែលមានការជំទាស់មួយត្រូវបានធ្វើឡើងដូចមានចែងក្នុងមាត្រានេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវ :

ក-ឱ្យជនជំទាស់នោះពន្យល់ឱ្យបានច្បាស់លាស់នូវមូលហេតុនៃការជំទាស់ និង

ខ-ដោះស្រាយការជំទាស់នោះដោយសមស្រប ។

៤-នៅពេលដែលស្តង់ដារបញ្ញាមួយត្រូវបានសំរេចរួចហើយ ជនទាំងអស់ដែលពាក់ព័ន្ធក្នុងដំណាក់ការផលិតកម្ម ត្រូវតែធានាអនុវត្តឱ្យបានត្រឹមត្រូវតាមស្តង់ដារបញ្ញានោះ ។

៥-នៅពេលដែលស្តង់ដារបញ្ញាត្រូវបានសំរេចរួច ឬស្តង់ដារមួយផ្សេងទៀតដែលត្រូវបានសំរេចឱ្យទៅ ជាស្តង់ដារបញ្ញា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយតំរូវឱ្យផលិតករស្នើសុំអាជ្ញាប័ណ្ណសំរាប់ផលិតផល ឬសំរាប់ខ្សែសង្វាក់ផលិតកម្ម ដោយអនុវត្តទៅតាមស្តង់ដារបញ្ញានោះ ចាប់ពីថ្ងៃដែលបានកំណត់បញ្ជាក់នៅក្នុងប្រកាស ។

៦-នៅពេលដែលស្តង់ដារបញ្ញាមួយត្រូវបានសំរេចដូចមានចែងក្នុងមាត្រា១៩ កថាខ័ណ្ឌទី៥ ក្រោយដែលបានកំណត់បញ្ជាក់ក្នុងប្រកាសនោះ គ្មានផលិតករណាអាចផលិត ឬបន្តផលិតនូវផលិតផលណាមួយ ឬរៀបចំខ្សែសង្វាក់ផលិតកម្មណាមួយតាមស្តង់ដារបញ្ញានោះបានឡើយ លុះណាតែបានស្នើសុំ និងបានទទួលអាជ្ញាប័ណ្ណស្តង់ដារបញ្ញាពីក្រសួងឧស្សា ហកម្ម រ៉ែ និងថាមពល ជាមុនសិន ។

៧-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចដកចេញនូវប្រកាសស្តីពីស្តង់ដារបញ្ញាដែលបានចេញរួចហើយ ដូចមានចែងក្នុងមាត្រា១៩ កថាខ័ណ្ឌទី១ ឬ កថាខ័ណ្ឌទី៥ បើយល់ថាចាំបាច់ ។

៨-ស្តង់ដារបញ្ញាដែលពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ ត្រូវយោងតាមការកំណត់របស់រដ្ឋ ។

**មាត្រា ២០ .-**

អ្នកស្នើសុំត្រូវបង់កំរៃសេវាក្នុងការសុំអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជីតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# ជំពូកទី ៤

# សិទ្ធិរបស់មន្ត្រីមានសមត្ថកិច្ច

## មាត្រា ២១ .-

មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិ :

១-ចូលទៅគ្រប់ទីកន្លែងផលិតរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាសណាមួយដែលបានទទួលអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រចុះបញ្ជី ឬខ្សែសង្វាក់ផលិតកម្ម ដែលទាក់ទងទៅនឹងការប្រើសញ្ញាសំគាល់ ដើម្បីត្រួតពិនិត្យទីកន្លែងដែលមានការមន្ទិលសង្ស័យ ទៅលើខ្សែសង្វាក់ផលិតកម្ម ផលិតកម្មប្រព្រឹត្តិកម្ម ដែលកំពុងដំណើរការ ឬឃ្លាំងស្តុកនៅគ្រប់ពេលម៉ោងមានសកម្មភាព ។

២-ចុះធ្វើអធិការកិច្ច និងយកគំរូតាំង នៅទីតាំងផលិត :

ក-ផលិតផលណាដែលបានប្រើសញ្ញាសំគាល់

ខ-សំភារៈ ឬ សារធាតុណាដែលបានប្រើ ឬមានការមន្ទិលសង្ស័យថា គុណភាពមិនសមស្របតាមស្តង់ដារកំណត់ក្នុងការផលិត ។

៣-បើកកញ្ចប់ ប្រអប់ កំប៉ុង ឬធុងណាមួយនៅនឹងទីកន្លែង បើមានការសង្ស័យ ។

៤-ចូលទៅកាន់ទីកន្លែងណាដែលបានប្រើប្រាស់ស្តង់ដារបញ្ជា ឬ សញ្ញាសំគាល់ស្តង់ដារផលិតផល ឬ ខ្សែសង្វាក់ផលិតកម្មណាមួយ ហើយត្រូវត្រួតពិនិត្យរាល់ការប្រតិបត្តិណាដែលបានដាក់ឱ្យអនុវត្ត ។

៥-ឃាត់ទុកផលិតផលក្នុងករណីដែលពិនិត្យឃើញច្បាស់ថា :

ក-ផលិតផលនោះមិនស្របតាមស្តង់ដារឧស្សាហកម្មកម្ពុជា

ខ-ផលិតផលនោះត្រូវបានគេបិទសញ្ញាស្តង់ដារ ក្នុងន័យបំភាន់ឱ្យមានការយល់ច្រឡំ ។

៦-តំរូវឱ្យនិយោជករៀបចំប្រមូល និងបង្ហាញឯកសារដែលទាក់ទងទៅនឹងផលិតផល ឬខ្សែសង្វាក់ផលិតកម្មរបស់ខ្លួន ដែលទាក់ទងទៅនឹងក្រុមហ៊ុន រោងចក្រ សហគ្រាសដែលបានបញ្ជាក់ក្នុង មាត្រា២១ កថាខ័ណ្ឌទី១ ។

៧-ពិនិត្យ ថតចំលង ឬសរសេរដកស្រង់ពីឯកសារដែលបានបញ្ជាក់ក្នុងមាត្រា២១ កថាខ័ណ្ឌទី៦ ឬថតរូបភាពដែលចាំបាច់ទុកជាឯកសារភស្តុតាង ។

**មាត្រា ២២ .-**

ចំពោះផលិតផលដែលបានឃាត់ទុកដោយមន្ត្រីមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា២១ កថាខ័ណ្ឌទី៥ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិដូចតទៅ :

១-ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណបានរំលោភលើមាត្រា១៣ កថាខ័ណ្ឌទី១ ឬក្នុងករណីដែលខកខានមិនបានបំពេញឱ្យស្របតាមមាត្រា១៣ កថាខ័ណ្ឌទី៦ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចសំរេចឱ្យដកសញ្ញាសំគាល់ស្តង់ដារនោះចេញ ។

២-ក្នុងករណីបើសញ្ញាសំគាល់ស្តង់ដារនោះមិនអាចដកចេញបាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវរៀបចំបែបបទតាមនីតិវិធីនៃច្បាប់ជាធរមាន ។

ចំពោះគ្រប់ករណីទាំងអស់ ការចំណាយត្រូវជាបន្ទុករបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬ ផលិតករទៅតាមករណីជាក់ស្តែង ។

## ជំពូកទី ៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា២៣.-**

ផលិតផល ឬខ្សែសង្វាក់ផលិតកម្មដែលបានអនុលោមទៅតាមស្តង់ដារណាមួយ ឬសញ្ញាសំគាល់ដែលបានប្រើភ្ជាប់ទៅនឹងផលិតផល ឬខ្សែសង្វាក់ផលិតកម្មណាមួយ មិនត្រូវបានលើកជាលេសមកអះអាង ដើម្បីតវ៉ាប្រឆាំងទៅនឹងបទប្បញ្ញត្តិរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលឡើយ ។

**មាត្រា២៤.-**

ដើម្បីរក្សាការសំងាត់ :

១-គ្មានមន្ត្រីណាម្នាក់អាចធ្វើឱ្យលេចចេញនូវរឿងអ្វី ដែលខ្លួនបានចេះដឹងក្នុងពេលហាត់រៀនធ្វើការ ឬបំពេញបេសកកម្មដែលទាក់ទងទៅនឹងរូបមន្ត ផលិតកម្ម ខ្សែសង្វាក់ផលិតកម្ម ឬប្រព្រឹត្តិកម្មដែលមានចែងក្នុងអនុក្រឹត្យនេះឡើយ លើកលែងតែស្ថិតក្នុងគោលបំណងដែលទាក់ទងទៅនឹងការងាររដ្ឋបាលក្នុងអនុក្រឹត្យនេះ ។

២-ចំពោះការបញ្ចេញនូវពត៌មានដែលទាក់ទងទៅនឹងរូបមន្ត ផលិតកម្ម ខ្សែសង្វាក់ ផលិតកម្ម ឬប្រព្រឹត្តិកម្មឱ្យដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬដល់ជនណាម្នាក់សំរាប់គោលបំណងការងាររដ្ឋបាលក្នុងអនុក្រឹត្យនេះ មិនត្រូវឱ្យមានការប៉ះពាល់ទៅលើការអនុវត្តន៍

ប្រកាសនីយប័ត្រតក្កកម្ម ដែលមានចែងនៅក្នុងច្បាប់ទាក់ទងទៅនឹងការការពារកម្មសិទ្ធបញ្ញាឡើយ ។

**មាត្រា២៥.-**

គ្មានជនណាម្នាក់អាចប្រើឈ្មោះមួយដែលក្នុងនោះមានពាក្យស្រដៀង ទៅនឹងពាក្យស្តង់ដារឧស្សាហកម្មកម្ពុជា ISC ឬ ប្រើសញ្ញាសំគាល់ណាមួយដើម្បីធ្វើពាណិជ្ជកម្ម ឬមុខជំនួញណាមួយក្នុងបំណងបំភាន់ឱ្យគេយល់ច្រឡំថា ការអះអាងរបស់ជននោះត្រូវបានធ្វើទៅតាមស្តង់ដារឧស្សាហកម្មកម្ពុជាបានឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខអក្សររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ៦

## ទោសពិន័យ

**មាត្រា២៦.-**

ជនណាដែលមិនអនុវត្តតាមបទបញ្ញានានាដែលបានចែងក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តល្មើស ។

**មាត្រា២៧.-**

ជនណាដែលមិនបានអនុវត្តតាមមាត្រា ១៤ ត្រូវពិន័យជាប្រាក់ពី ២៥០.០០០ រៀល ( ពីររយហាសិបពាន់រៀល) ដល់ ៥០០ ០០០ រៀល ( ប្រាំរយពាន់រៀល) ។

**មាត្រា២៨.-**

អ្នកកាន់អាជ្ញាប័ណ្ណដែលមិនបានគោរពតាមមាត្រា១៥ ត្រូវពិន័យជាប្រាក់ពី ៣០០.០០០ រៀល ( បីរយពាន់រៀល ) ដល់ ៦០០ ០០០ រៀល ( ប្រាំមួយរយពាន់រៀល) ។

**មាត្រា២៩.-**

ជនណាដែលរំលោភមាត្រា ១៩ កថាខ័ណ្ឌទី៤ ឬកថាខ័ណ្ឌទី៥ ឬ កថាខណ្ឌទី៦ ត្រូវពិន័យជាប្រាក់ពី ១.០០០.០០០ រៀល ( មួយលានរៀល) ដល់ ២.០០០ ០០០ រៀល ( ពីរលានរៀល) ។

**មាត្រា៣០.-**

ជនណាដែលរំលោភមាត្រា ១៣ កថាខ័ណ្ឌទី៦ ត្រូវពិន័យជាប្រាក់ពី ២.០០០.០០០ រៀល ( ពីរលានរៀល) ដល់ ៥.០០០ ០០០ រៀល ( ប្រាំលានរៀល) ។

មាត្រា៣១.-

ជនណាដែលរារាំងមន្ត្រីមានសមត្ថកិច្ចក្នុងពេលបំពេញភារកិច្ចមាត្រា ២១ ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល ( ប្រាំលានរៀល) ដល់ ៨.០០០ ០០០ រៀល ( ប្រាំបីលានរៀល) ។

មាត្រា៣២.-

ជនណាដែលរំលោភនិងរារាំងមន្ត្រីមានសមត្ថកិច្ចក្នុងពេលបំពេញភារកិច្ច តាមមាត្រា២២ ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល ( ប្រាំលានរៀល)ដល់ ១០.០០០.០០០ រៀល ( ដប់លាន រៀល)

មាត្រា៣៣.-

មន្ត្រីមានសមត្ថកិច្ចណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬរួមគំនិតជាមួយជនល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើស នោះត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

មាត្រា៣៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
ហត្ថលេខា
**ស៊ុយ សែម**

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

***